

**អាខ្វាក់ អាខ្វិន** ធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃក៏មកដល់ស្រុកមួយ ស្រុកនោះមានសាលាដំណាក់មួយដែលជាកន្លែងសម្រាប់ដាក់មនុស្សឱ្យយក្សស៊ី។ ថ្ងៃដែល **អាខ្វាក់ អាខ្វិន** ទៅដល់ មានស្ដេចមួយអង្គកំពុងនាំ **នាងពៅ** ជាព្រះរាជបុត្រីតែមួយ យកមកប្រគល់ឱ្យយក្សស៊ីជាចំណី ព្រោះយក្សនោះចង់ស៊ី **នាងពៅ** នេះណាស់ បើមិនឱ្យព្រះនាងទៅយក្សស៊ីទេ នោះវានឹងស៊ីមនុស្សក្នុងព្រះនគរទាំងអស់។ **នាងពៅ** អាណិតអស់រាស្ត្រ នាម៉ឺន និង ព្រះបិតា ក៏សុខចិត្តប្រគល់ខ្លួនមកឱ្យយក្សស៊ីតាមបំណង។

ជួនជាថ្ងៃនោះដែរ ពួកគេបានទៅដល់សាលាដំណាក់នោះ។ **អាខិន** ប្រាប់ **អាខ្វាក់** ថា "ឥឡូវយើងមកដល់សាលាដំណាក់មួយ យើងឈប់មួយភ្លែតទៅ"។ ដូច្នេះ ពួកគេក៏សម្រេចចិត្តចូលសម្រាកនៅទីនោះ។



៦ **នាងពៅ** នៅក្នុងស្គរព្រមាត់ពួកគេជជែកគ្នាក៏ចេញមកសួរថា "អ្នកទាំងពីរមកពីណា ត្បិតសាលានេះ ជាកន្លែងសំរាប់ដាក់មនុស្សឱ្យយក្សស៊ីតែប៉ុណ្ណោះ ពេលព្រលប់យក្សហោះមកស៊ីមនុស្សនៅទីនេះ ឯខ្លួនខ្ញុំ គឺជាចំណីរបស់យក្ស។ ដូច្នេះ ចូរអ្នកចេញទៅវិញឱ្យឆាប់ឡើង បើនៅ មុខជាយក្សស៊ីអ្នកជាចំណីមិនខានឡើយ"។





ចំណែក **អាខ្វាក់** ហេតុតែជាមនុស្សខ្វាក់ពីកំណើតមិនដែលចេះខ្លាចអ្វីផងនោះក៏ឆ្លើយឡើងថា "ខ្លាចអីយក្សនោះ បើវាមក យើងនឹងកាប់វាឱ្យងាប់"។ **នាងពៅ** ឮ **អាខ្វាក់** និយាយដូច្នេះ ក៏ប្រាប់ទៅវិញថា "បើអ្នកសម្លាប់យក្សនោះបាន របស់ទ្រព្យទាំងប៉ុន្មានដែលគេយកមកឱ្យយក្សនោះ ខ្ញុំជូនអ្នកទាំងអស់"។ **អាខ្វាក់** ឮដូច្នោះអរណាស់ បង្គាប់ **អាខ្វិន** ថា "**អាខ្វិន!** ឯងយកបាយនំចំណីឱ្យអញស៊ី នឹងអាលមានកំលាំងសម្លាប់យក្ស"។ **អាខ្វិន** គ្រាន់តែឮយក្សមកស៊ី ភ័យស្ទើរនឹងស្លាប់។ **អាខ្វាក់** ស៊ីបាយឆ្អែតហើយបិទទ្វារសាលាជិត។

លុះដល់ពេលព្រលប់បន្តិច ល្មមវេលាយក្សមកដល់ព្រសន្ធឹកដូចព្យុះ លាន់ខ្ទរទាំងដី។ **អាខ្វិន** ភ័យណាស់ស្ទើរនឹងលេចអាចម៍លេចនោម **នាងពៅ** ក៏សន្លប់ក្នុងស្គរ។ **អាខ្វាក់** ព្រសន្ធឹកយក្សមកមិនខ្លាចអង្គុយចាំនៅមាត់ទ្វារ។



លុះពេលយក្សមកដល់ឃើញទ្វារសាលាបិទ យក្សស្រែកសន្ធាប់ដូចរន្ទះថា "នរណាបិទទ្វារសាលាអញ?"។ **អាខ្វាក់** មិនខ្លាចយក្សឆ្លើយថា "អញបិទទ្វារសាលាអញ ខ្លាចអីអាឯងនោះ"។ យក្សសួរថា "មនុស្សមកពីណា ចិត្តអីក៏ធំម្ល៉េះ ថ្លើមឯងប៉ុណ្ណាបានជាហ៊ានដល់ម្លឹង?" **អាខ្វាក់** បោះចង្កេះគ្រោងទៅឱ្យយក្ស យក្សមើលឃើញចង្កេះនោះភ្លាមគិតថា "ថ្លើមអានេះធំណាស់ មិនដឹងខ្លួនវាធំប៉ុណ្ណាទេ" បើថ្លើមឯងធំប៉ុណ្ណេះ ចុះថៃឯងធំប៉ុណ្ណាទៅ?" យក្សសួរបន្ត។ **អាខ្វាក់** បោះអណ្ដើកទៅឱ្យយក្សៗស្មានថាថៃមែនគិតថា "ថៃវាធំប៉ុណ្ណេះ ខ្លួនរបស់វាមិនដឹងជាធំប៉ុណ្ណាទេ" ចុះរោមជើងឯងធំប៉ុណ្ណាទៅ?" យក្សសួរបន្ត។ **អាខ្វាក់** បោះខ្សែពួរទៅឱ្យយក្សមើលហើយប្រាប់ថា "នេះជារោមជើងរបស់អញ"។ យក្សគ្រាន់តែឃើញខ្សែពួរភិតភ័យជាខ្លាំងរត់ដាក់មេប្រូចមិនត្រឡប់ក្រោយឡើយ។

**អាខ្វាក់** ប្រាប់ **នាងពៅ** ថា "យក្សរត់បាត់ហើយ ត្បិតវាខ្លាចខ្ញុំ យក្សមិនហ៊ានមកទីនេះទៀតទេ"។ **នាងពៅ** ក្រោកពីភ័យសន្លប់ ក៏ប្រាប់ **នាយខ្វាក់** ថា "មានយក្ខិនីមួយទៀត យប់បន្តិចវានឹងមក"។ **អាខ្វាក់** ឮ **នាងពៅ** និយាយដូច្នេះ ក៏ប្រាប់ **អាខ្វិន** ថា "**អាខ្វិន** ឯងទៅរើសដាវមួយណាវែង ហើយមុតសមល្មមនឹងកំលាំងអញ" **អាខ្វិន** ក៏រើសបានដាវមួយសមចិត្ត **អាខ្វាក់** ។

លុះយប់បន្តិច យក្ខិនីនោះហោះមកព្រួសន្ទឹកដូចផ្គរ។ **អាខ្វាក់** បិទទ្វារត្រៀមខ្លួនរួចជាស្រេច ឈរកាន់ដាវនៅមាត់ទ្វារ។ ពេលយក្ខមកដល់ វាច្រានទ្វារអើតកចូលមក **អាខ្វាក់** ព្រួសន្ទឹកយក្ខច្រានទ្វារ ក៏កាប់ត្រូវយក្ខដាច់កស្លាប់នៅនឹងកន្លែង។ **អាខ្វាក់** **អាខ្វិន** ដឹងថាយក្ខស្លាប់ហើយ ក៏បបួលគ្នាយកមាសប្រាក់នោះចេញទៅ។



លុះពេលព្រឹកឡើង **អាខ្វិន** ឃើញដើមក្រសាំងមួយប្រាប់ **អាខ្វាក់** ឱ្យចូលទៅនឹងចែករបស់គ្នា។ **អាខ្វាក់** ក៏ដាក់ **អាខ្វិន** ចុះពីលើស្មា យករបស់មកចែកគ្នា **អាខ្វិន** ធ្វើជាមេចំណែក រើសរបស់ល្អៗដាក់ខាងមុខខ្លួន ហើយដាក់របស់មិនល្អដាក់ខាងមុខ **អាខ្វាក់** ទើបសួរថា "**អាខ្វាក់** ឯងយករបស់ខាងមុខឯង ឬរបស់ខាងមុខអញ?"



**អាខ្វាក់** មានប្រាជ្ញាគិតថា **អាខ្វិន** ប្រហែលជាយករបស់អន់ដាក់នៅមុខខ្លួន ក៏ប្រាប់ទៅ **អាខ្វិន** ថា "អញយករបស់នៅមុខឯង"។ **អាខ្វិន** ដឹងថា **អាខ្វាក់** យករបស់ល្អក៏ប្រាប់ទៅ **អាខ្វាក់** ថា "ចែកម្តងទៀត ចែកមិនទាន់ស្មើគ្នាទេ" **អាខ្វិន** ដូររបស់ល្អដាក់នៅខាងមុខ **អាខ្វាក់** ហើយសួរថា "ឯងយកខាងណា?" **អាខ្វាក់** គិតថា "ម្តងនេះប្រហែលជា **អាខ្វិន** យករបស់ល្អមកដាក់ខាងមុខអញហើយ" ហើយយកដៃស្ទាបរបស់នៅមុខខ្លួនឆ្លើយថា "អញយករបស់នៅខាងមុខអញ"។ **អាខ្វិន** ឃើញ **អាខ្វាក់** បានរបស់ល្អក៏និយាយថា "ចែកមិនត្រូវទេ ត្រូវចែកម្តងទៀត"។ **អាខ្វាក់** ឆ្លើយថា "ឯងចែកខ្លួនឯងហើយ នៅថាចែកមិនត្រូវទៀត"។

**អាខ្វាក់** **អាខ្វិន** ប្រកែកគ្នាទៅវិញទៅមក ស្រាប់តែផ្លែក្រសាំងមួយជ្រុះមកត្រូវក្បាល **អាខ្វាក់ៗ** គិតស្មានថា **អាខ្វិន** វាយក៏និយាយថា "យីអើ ត្រឹមតែមាត់មិនអស់ចិត្តដៃដល់ទៀត"។ **អាខ្វាក់** ក៏លើកជើងធាក់ **អាខ្វិន** ទាល់តែជើងត្រង់ទាំងសងខាង។ ឯ **អាខ្វិន** ខឹងណាស់ក៏ក្តាប់ដៃដាល់ **អាខ្វាក់** ត្រូវភ្នែកៗ **អាខ្វាក់** ក៏ភ្លឺច្បាស់ទាំងសងខាង អ្នកទាំងពីរភ្ញាក់ផ្អើលយ៉ាងខ្លាំង ក៏បាត់ខឹងរៀងខ្លួន ហើយបបួលគ្នាធ្វើដំណើរទៅមុខទៀត។



និយាយពី **នាងពៅ** ព្រឹកឡើងអស់មនុស្សម្នាគេមកមើល ឃើញនាងនៅរស់ ហើយឃើញយក្ខងាប់ចង្រ្កាងនៅមាត់ទ្វារ អស់មនុស្សក៏ចូលទៅក្រាបទូលស្ដេចតាមដំណើរ។ ទ្រង់មានព្រះរាជហឫទ័យត្រេកអរខ្លាំងណាស់ក៏មានបន្ទូលសួរបុត្រីថា "ដូចម្ដេចបានជាបុត្ររួចផុតពីកណ្ដាប់ដៃយក្ខ ហេតុអ្វីបានជាយក្ខស្លាប់ទៅវិញ?" **នាងពៅ** ក៏ទូលព្រះបិតាតាមដំណើររឿងទាំងស្រុង។



ទ្រង់បញ្ជាសេនាប្រកាសរកអ្នកដែលសម្លាប់យក្ខ ទ្រង់នឹងប្រទាន **នាងពៅ** ជាព្រះមហេសី ហើយឱ្យឡើងសោយរាជ្យជាស្ដេចផែនដី។ រាជអាមាត្យបានប្រកាសគ្រប់ស្រុកភូមិ។ **អាខ្វាក់ អាខ្វិន** បានជួបក៏ត្រេកអរជាខ្លាំងប្រាប់សេនាថា "រូបខ្ញុំនេះហើយ ជាអ្នកសម្លាប់យក្ស បើមិនជឿ ខ្ញុំមានរបស់ដែលបានអំពីយក្សជាសំគាល់"។ រាជអាមាត្យក៏នាំអ្នកទាំងពីរទៅថ្វាយស្ដេច។



លុះទៅដល់ព្រះរាជវាំង **នាយខ្វាក់** និង **នាយខ្វិន** ប្រញាប់ចូលគាល់ស្តេចក្រាបទូលតាមដំណើររឿងទាំងអស់។ ស្តេចហៅ **នាងពៅ** មកជួបហើយមានព្រះបន្ទូលថា "បុត្រីបិតា តើបុរសពីរនាក់នេះឬ ដែលជាអ្នកសម្លាប់យក្សនោះ?" ព្រះនាងទូលព្រះអង្គថា "ក្រាបទូលព្រះបិតា គាត់នេះហើយជាបុរសក្លាហានសម្លាប់យក្សបាន តែពីមុន ពួកគាត់ខ្វាក់ខ្វិន ឥឡូវមិនខ្វាក់ខ្វិនទៀតទេ"។



ស្ដេចទ្រង់ជ្រាបប្រាកដហើយ ទ្រង់ក៏ផ្សំផ្គុំបុត្រីរៀបអភិសេកជាមួយ **នាយខ្វាក់** ឡើងសោយរាជ្យជំនួសព្រះអង្គ។ ចំណែក **នាយខ្វិន** ធ្វើជាឧបរាជ ត្បិតជាមនុស្សកំសត់កម្រជាមួយគ្នា បានសុខសាន្តជារៀងដរាបតទៅ។ **ចប់**



ភ្នែកសាច់ មិនសម្រេចដូចភ្នែកប្រាជ្ញា